*សេចក្តីប្រកាសព័ត៌មាន*

# អង្គការមូលនិធិបង្ការរបួស អាស៊ី និងទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការ អភិវឌ្ឍន៍អន្តរជាតិ សហការគ្នាដើម្បីរួមចំណែកជួយប្រទេសកម្ពុជាពី ការខាតបង់ថវិការាប់លានដុល្លា

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤

អង្គការមូលនិធិបង្ការរបួស អាស៊ី (AIP Foundation) ដែលជាអង្គការមិនមែនរដ្ឋាភិបាល និងមិនស្វែងរកប្រាក់ចំណេញ បានទទួលការគាំទ្រជាមូលនិធិចំនួន ៦៣៥ ៩៩៣ ដុល្លាសហរដ្ឋអាមេរិចពីកម្មវិធី Development Innovation Ventures (DIV) របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ (USAID)។ ដោយមានការសហការគាំទ្រពីគណៈកម្មាការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងក្រសួងមហាផ្ទៃ ជំនួយនេះនឹងផ្តល់លទ្ធភាពដល់អង្គការមូលនិធិបង្ការរបួស អាស៊ី អនុវត្តគម្រោង "មួកសុវត្ថិភាពមួយ ជួយជីវិតបានម្នាក់" ដែលមានរយៈពេលពីរឆ្នាំក្នុងគោលបំណងបង្កើនការពាក់មួកសុវត្ថិភាពក្នុងប្រទេសកម្ពុជា។ ថវិកាបដិភាគប្រមាណជាង ៦៥០ ០០០ ដុល្លាសហរដ្ឋអាមេរិចផ្សេងទៀត ក៏ត្រូវបានផ្តល់ដោយម្ចាស់ជំនួយជាច្រើនដូចជា៖ មូលនិធិសហព័ន្ធយានយន្តអន្តរជាតិ (FIA Foundation), មូលនិធិសុវត្ថិភាពចរាចរណ៍ (Road Safety Fund), មូលនិធិក្រុមហ៊ុន UPS, មជ្ឈមណ្ឌលសហរដ្ឋអាមេរិចដើម្បីបង្ការ និងគ្រប់គ្រងជម្ងឺ (US CDC) និងពីអង្គការមូលនិធិបង្ការរបួស អាស៊ី។

ថ្ងៃនេះអង្គការមូលនិធិបង្ការរបួសអាស៊ី បានបង្ហាញជូន និងចែករំលែកនូវពត៌មានស្តីពីសកម្មភាពសំខាន់ៗរបស់គម្រោង "មួកសុវត្ថិភាពមួយ ជួយជីវិតបានម្នាក់" នៅក្នុងសិក្ខាសាលាដៃគូថ្នាក់ជាតិនៅរាជធានីភ្នំពេញ។ សិក្ខាសាលានេះមានការចូលរួមពីដៃគូប្រមាណ ៥៥នាក់ ដែលជាមន្ត្រីមកពីស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត តំណាងដៃគូអភិវឌ្ឍន៍អន្តរជាតិសំខាន់ៗ និងមានវត្តមាន **ឯកឧត្តម ពៅ ម៉ាលី** អគ្គលេខាធិការគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និង **ឯកឧត្តម ឧត្តមសេនីយ៍ទោ ហ៊ឹម យ៉ាន** ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់នៃក្រសួងមហាផ្ទៃ អញ្ជើញចូលរួមជាអធិបតី។

**ឯកឧត្តម ឧត្តមសេនីយ៍ទោ ហ៊ឹម យ៉ាន** ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់នៃក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា៖ "គ្រោះថ្នាក់ចរាចរណ៍ គឺជាវិបត្តិផ្នែកសុខភាពសាធារណៈជាសកលមួយ ជាពិសេសសម្រាប់ព្រះរាជាណាចក្រកម្ពុជា ដោយគ្រោះថ្នាក់នេះបានសម្លាប់មនុស្សច្រើនជាងការស្លាប់ដែលបណ្តាលមកពីគ្រាប់មីន ឬដោយសារជម្ងឺគ្រុនចាញ់ទៅទៀត"។ **ឯកឧត្តម** បានមាន

ប្រសាសន៍បន្ថែមទៀតថាៈ “គ្រាន់តែក្នុងឆ្នាំ២០១៣ប៉ុណ្ណោះ គ្រោះថ្នាក់ចរាចរណ៍បានបង្កឱ្យមានអ្នករងរបួសរហូតដល់ទៅ ១៤,២២៧នាក់ និងបានផ្តាច់ជីវិតមនុស្សចំនួន ១,៩៥០នាក់ ដែលភាគច្រើនគឺជាយុវជន ហើយធ្វើអោយប្រទេសកម្ពុជាខាតបង់ថវិកាអស់ប្រមាណ ៣៣៧លានដុល្លារ ស្មើនឹង ២.១ភាគរយផលិតផលក្នុងស្រុកសរុប”។

លោកស្រី មើរ៉ាម ស៊ីឌីត ប្រធាននាយិកាប្រតិបត្តិនៃអង្គការមូលនិធិបង្ការរបួស អាស៊ី មានប្រសាសន៍ថាៈ “នៅប្រទេសកម្ពុជា ទោចក្រយានយន្ត (ម៉ូតូ) ជាមធ្យោបាយធ្វើដំណើរដ៏សំខាន់។ អ្នកបើកបរ និងអ្នករួមដំណើរតាមទោចក្រយានយន្ត គឺជាប្រភេទអ្នកប្រើប្រាស់ផ្លូវដែលមានអត្រាគ្រោះថ្នាក់ចរាចរណ៍ខ្ពស់បំផុត។ នៅក្នុងឆ្នាំ២០១៣ ប្រមាណ ៦២ ភាគរយនៃជនរងគ្រោះដល់ស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ ទទួលរងការរងរបួសក្បាល។ ជនរងគ្រោះដែលនៅមានជីវិតប្រឈមមុខនឹងស្ថានភាពអាក្រក់បំផុត”។ លោកស្រីបានបន្ថែមទៀតថា ការរងរបួសភាគច្រើនបានបណ្តាលអោយមានពិការភាពយូរអង្វែង ដែលតំរូវអោយមានការថែទាំ និងព្យាបាលជាប្រចាំ។ បន្ថែមពីលើការឈឺចាប់ និងទុក្ខលំបាកដែលកើតមានសម្រាប់ខ្លួនឯងផ្ទាល់ បញ្ហានេះវាបានធ្វើមានផលប៉ះពាល់ជាអវិជ្ជមានដល់គ្រួសារ ប្រព័ន្ធសុខភាពសាធារណ និងសង្គមទាំងមូលផង។

យោងតាមការសិក្សាស្រាវជ្រាវរបស់ Cochrane Database of Systematic Reviews បានបង្ហាញថា ការពាក់មួកសុវត្ថិភាពគឺជាមធ្យោបាយដ៏សំខាន់ និងមានប្រសិទ្ធភាពមួយក្នុងការបង្កើនការនៅរស់រានមានជីវិតដោយវាអាចកាត់បន្ថយហានិភ័យនៃការស្លាប់រហូតដល់ ៤២ភាគរយ និងការរងរបួសក្បាលរហូតដល់ ៦៩ភាគរយ។ នៅប្រទេសកម្ពុជា អ្នកបើកបរទោចក្រយានយន្តត្រូវបានច្បាប់កំណត់ឱ្យពាក់មួកសុវត្ថិភាព ប៉ុន្តែអ្នករួមដំណើរជាមួយ គិតទាំងកុមារផងមិនទាន់ត្រូវបានតម្រូវឱ្យពាក់មួកសុវត្ថិភាពនៅឡើយទេ។ ជាអកុសល មានអ្នករួមដំណើរប្រមាណតែ ៩ភាគរយប៉ុណ្ណោះ ដែលបានពាក់មួកសុវត្ថិភាពនៅពេលធ្វើដំណើរតាមទោចក្រយានយន្ត។

លោក គឹម បញ្ញា នាយកអង្គការមូលនិធីបង្ការរបួសអាស៊ីប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថាៈ “គម្រោង “មួកសុវត្ថិភាពមួយ ជួយជីវិតបានម្នាក់” មានគោលបំណងធ្វើអោយអត្រាការពាក់មួកសុវត្ថិភាពសំរាប់អ្នករួមដំណើរនៅតាមឃុំគោលដៅមួយចំនួននៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺកើនឡើងរហូតដល់៣០ភាគរយ ក្នុងឆ្នាំទី១ និងឈានដល់កម្រិត ៨០ភាគរយនៅចុងឆ្នាំទី២ ដែលជាលទ្ធផលវាអាចជួយបង្ការនូវការរងរបួស និងការស្លាប់ពីគ្រោះថ្នាក់ចរាចរណ៍ជាច្រើនពាន់នាក់ ហើយនឹងរួមចំណែកជួយដល់ប្រទេសកម្ពុជាពីការខាតបង់ថវិកាបានជាច្រើនលានដុល្លាសហរដ្ឋអាមេរិច។

គោលដៅនៃគម្រោង នឹងសម្រេចបានតាមរយៈសមាសភាពសំខាន់ៗចំនួន៣ដែលបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក រួមមាន៖

១. កម្មវិធីអប់រំនៅតាមគ្រឹះស្ថានសិក្សា ដែលនឹងរួមចំណែកបង្កើតឱ្យមានអ្នកប្រើប្រាស់ផ្លូវដែលមានសុវត្ថិភាពនៅក្នុងជំនាន់ថ្មីមួយ
២. យុទ្ធនាការអប់រំផ្សព្វផ្សាយសាធារណៈ ដែលនឹងប្រើប្រាស់នូវប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្លាស់ប្តូរឥរិយាបទ និង
៣. យុទ្ធនាការទាក់ទាញមតិគាំទ្រ ដែលនឹងគាំទ្រដល់ដំណើរពន្លឿនការកែសម្រួលច្បាប់ និងបទបញ្ញត្តិនានា និងការអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព។

**ឯកឧត្តម ពៅ ម៉ាលី** អគ្គលេខាធិការ គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅកម្ពុជា បានមានប្រសាសន៍ថា៖ “ការបង្កើតឱ្យមាន និងការអនុវត្តគម្រោងដ៏សំខាន់នេះនៅប្រទេសកម្ពុជាគឺធ្វើឡើងក្នុងពេលវេលាដ៏សមស្របមួយ ដោយរាជរដ្ឋាភិបាលកម្ពុជាកំពុងតែបង្កើននូវកិច្ចខិតខំប្រឹងប្រែងក្នុងការឈានទៅអនុម័តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មី ហើយដែលអាចនឹងអនុម័តចប់រួចរាល់នៅក្នុងពេលឆាប់ៗខាងមុខនេះ។ ច្បាប់ថ្មីនេះនឹងអនុវត្តចំពោះការពាក់មួកសុវត្ថិភាពសំរាប់អ្នកជិះទោចក្រយានយន្តទាំងអស់ រួមទាំងកុមារផង”។

គម្រោងនេះត្រូវបានបង្កើតឡើងដោយផ្អែកលើគំរូនៃអន្តរាគមន៍ការងាររបស់អង្គការមូលនិធិបង្ការរបួស អាស៊ី នៅក្នុងប្រទេសវៀតណាមដែលបានជម្រុញឲ្យមានច្បាប់ស្តីពីការពាក់មួកសុវត្ថិភាពក្នុងឆ្នាំ២០០៧។ ជាលទ្ធផលការអនុវត្តច្បាប់នេះបានជួយសង្គ្រោះជីវិតមនុស្សប្រមាណ ១ ៥៥៧នាក់ ការពារការរងរបួសបាន ២ ៩៩៥នាក់ និងកាត់បន្ថយការខាតបង់ថវិការបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាលវៀតណាមបាន ៥២លានដុល្លា ដែលត្រូវចំណាយលើការខាតបង់ការងារ ថ្លៃព្យាបាល និងតម្លៃនៃផលប្រយោជន៍ចំពោះការរួមចំណែកអភិវឌ្ឍសង្គមនៅក្នុងឆ្នាំដំបូង។

គម្រោង “មួកសុវត្ថិភាពមួយ ជួយជីវិតបានម្នាក់” នឹងផ្តល់ប្រយោជន៍ដោយផ្ទាល់ទៅដល់ប្រជាពលរដ្ឋកម្ពុជាប្រមាណជាង ២២២ ៩៤៥នាក់ តាមរយៈការផ្តល់មួកសុវត្ថិភាព (ដោយឥតគិតថ្លៃ និងក្នុងតម្លៃឧបត្ថម្ភ) និងការអប់រំអំពីសុវត្ថិភាពចរាចរណ៍ ហើយប្រជាពលរដ្ឋប្រមាណ ១ ៦៣៤ ៥៥៥នាក់ផ្សេងទៀត នឹងទទួលបានអត្ថប្រយោជន៍ដោយប្រយោលនៅក្នុងអំឡុងពេលអនុវត្តគម្រោងនេះ។ កម្មវិធី Development innovation Ventures (DIV) នៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិបានផ្តល់ថវិកាចំនួន ៦៣៥ ៩៩៣ ដុល្លារសហរដ្ឋអាមេរិចក្នុងគោលបំណងជួយការពារការខាតបង់ថវិកាសំរាប់រាជរដ្ឋាភិបាលកម្ពុជាចំនួនប្រមាណ ១,៧លានដុល្លាសហរដ្ឋអាមេរិក។ ប្រសិនបើថវិកាគាំទ្រទាំងនេះ មាននិរន្តរ៍ភាពក្នុងរយៈពេល ១០ឆ្នាំ មានការប៉ាន់ប្រមាណថាការវិនិ

យោគត្រលប់មកវិញនឹងកើនឡើងពី ២,៨ដុល្លាសហរដ្ឋអាមេរិច ទៅដល់ ១៤,៩ដុល្លាសហរដ្ឋអាមេរិច។ បើនិយាយតាមមួយបែបទៀត គឺរាល់ការចំណាយ១ដុល្លាសហរដ្ឋអាមេរិចរបស់គម្រោងនឹងជួយការពារការខាតបង់ថវិការហូតដល់១៤,៩ដុល្លាសហរដ្ឋអាមេរិច។

ការបង្កើតឡើងនូវសមាសភាពសំខាន់ៗនៃគម្រោង នឹងធ្វើឡើងដោយផ្អែកលើលទ្ធផលនៃការរកឃើញពីការប៉ាន់ប្រមាណដែលនឹងធ្វើឡើងនៅពេលចាប់ផ្តើមដំបូងនៃគម្រោងនេះ។ ការតាមដានត្រួតពិនិត្យប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ តាមរយៈការអនុវត្តន៍វិធីសាស្រ្តការអង្កេតការពាក់មួកសុវត្ថិភាពរៀងរាល់ត្រីមាស ដោយប្រើប្រាស់វិធីសាស្រ្តថតយករូបភាពជាវីដេអូ និងការវាយតំលៃនៅពាក់កណ្តាលគម្រោង រហូតដល់ចប់ការអនុវត្តន៍គម្រោង។ សកម្មភាពទាំងនេះនឹងជួយចង្អុលបង្ហាញពីការវិវឌ្ឍន៍រីកចម្រើន បញ្ហាប្រឈមនានា និងផ្តល់លទ្ធភាពក្នុងការកែសម្រួលគម្រោង ធ្វើយ៉ាងណាឱ្យការអនុវត្តន៍គម្រោងបានកាន់តែប្រសើរឡើង ហើយនឹងរួមចំណែកដល់ការពង្រីកគម្រោងនៅពេលអនាគត។

## អំពីអង្គការមូលនិធិបង្ការរបួសអាស៊ី

អង្គការមូលនិធិបង្ការរបួស អាស៊ី គឺជាអង្គការមិនមែនរដ្ឋាភិបាល និងមិនស្វែងរកប្រាក់ចំណេញដែលមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបង្ការការរងរបួស និងការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍នៅក្នុងបណ្តាប្រទេសដែលមានចំណូលទាប និងមធ្យម។ អស់រយៈពេល១៥ឆ្នាំមកហើយដែលអង្គការមូលនិធិបង្ការរបួស អាស៊ី បានអនុវត្តកម្មវិធីសុវត្ថិភាពចរាចរណ៍ដ៏មានប្រសិទ្ធភាពនៅបណ្តាប្រទេសជាច្រើនរួមមាននៅទ្វីបអាស៊ី និងទ្វីបអាហ្វ្រិច។ ដើម្បីស្វែងយល់បន្ថែមសូមចូលទស្សនាគេហទំព័រ asiainjury.org ឬភ្ជាប់ទំនាក់ទំនងជាមួយយើងខ្ញុំនៅលើ Twitter @AIPFoundation.

## អំពីកម្មវិធី Development Innovation Ventures (DIV) នៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ

កម្មវិធី Development Innovation Ventures (DIV) នៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ គឺជាកម្មវិធីវិនិយោគមួយដែលស្វែងរក ធ្វើការសាកល្បង និងពង្រីកដំណោះស្រាយថ្មីៗចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍន៍នៅទូទាំងពិភពលោក។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទស្សនាគេហទំព័រ www.usaid.gov/div ឬទំនាក់ទំនងជាមួយយើងខ្ញុំនៅលើ Twitter@DIVatUSAID។

## សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

លោក គឹម បញ្ញា
នាយក អង្គការមូលនិធិបង្ការរបួស អាស៊ី ប្រចាំនៅកម្ពុជា

AIP FOUNDATION
MAKING ROADS SAFE

USAID
FROM THE AMERICAN PEOPLE

ផ្ទះលេខ ១៨បេអឹ០ ផ្លូវលេខ ៣៩៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ ៨៥៥ ៩២៩ ២៣៩; អ៊ីម៉ែល៖ pagna.kim@aipf-cambodia.org ៕

##